***Acitivities 26: Community Scout Movement training for Muslim youth Leaders Presided over by H.E Nos Sles Secretary of youth and sport, 09 January 2020***







*សកម្មភាព 27៖ ឯកឧត្តម ណុះ ស្លេះ រដ្ឋលេខាធិការ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីជំនាញនៃក្រសួងអប់រំ យុវជន និងកីឡា ជួបពិភាក្សាការងារជាមួយអង្គភាពសាជីវកម្មជាតិម៉ាឡេស៊ី (ANGKASA) នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០*

***Activites 27: Courtesy call meeting of ANKASA Cooperative Leaders to H.E Nos Sles secretary of state Ministry of Education, Youth and Sport, on cooperative movement for Islamic education in Cambodia***

## ២.៣ ការចុះពង្រឹងដំណើរការបង្រៀន និងរៀន និងការគ្រប់គ្រងទិន្នន័យអប់រំឥស្លាម

***5.3 Activities of Muslim Leaders in charge of Islam Education to conduct Evaluation meeting and monitoring process for Islamic Education at Various part of the country.***

1. ខេត្តត្បូងឃ្មុំ Tboung Khmum Province៖ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ **ឯកឧត្តម ណុះ ស្លេះ** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ប្រធានប្រតិភូចុះពង្រឹងដំណើរការបង្រៀននិងរៀន និងការគ្រប់គ្រងទិន្នន័យអប់រំឥស្លាម មានការរួមដំណើរដោយ **ឯកឧត្តម សុះ ហ្វាសុី** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ថ្នាក់ដឹកនាំគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា និងក្រុមមន្ត្រីជំនួយការ ដែលមានការចូលរួមពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំនៃរដ្ឋបាលក្រុង ស្រុក និងលោកគ្រូ អ្នកគ្រូ( តួនៗ )នៅក្នុងខេត្តត្បូងឃ្មុំ ។







*Tbong Khmun Province: June 25, 2020, the Inspection and Teaching Inspection Ceremony was chaired by H.E Nos Sles, Secretary of State of the Ministry of Education, Youth and Sports, accompanied by H.E Sos Fasy, Undersecretary of State of the Ministry of Education Youth and Sport, Director of Khmer Islam Education and Khmer Islam Teachers at Department of Education youth ans sport in Tbong Khmum Province.*

2. ខេត្តកំពង់ចាម Kampong Cham Province: ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ **ឯកឧត្តម ណុះ ស្លេះ** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ប្រធានប្រតិភូចុះពង្រឹងដំណើរការបង្រៀននិងរៀន និងការគ្រប់គ្រងទិន្នន័យអប់រំឥស្លាម រួមដំណើរដោយ **ឯកឧត្តម សុះ ហ្វាស៊ី** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ថ្នាក់ដឹកនាំគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា និងក្រុមមន្ត្រីជំនួយការ ដែលមានការចូលរួមពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំនៃរដ្ឋបាលក្រុង ស្រុក និងលោកគ្រូ អ្នកគ្រូ(តួនៗ)នៅក្នុងខេត្តកំពង់ចាម។











*Kompong Cham Province: June 15, 2020, the Inspection and Teaching Inspection Ceremony was chaired by H.E Nos Sles, Secretary of State of the Ministry of Education, Youth and Sports, accompanied by H.E Sos Fasy, Undersecretary of State of the Ministry of Education Youth and Sport, Director of Khmer Islam Education and Khmer Islam Teachers at Department of Education youth and sport in Kompong cham Province.*

**3. ខេត្តមណ្ឌលគិរី Mondul Kiri Province៖** ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២០ **ឯកឧត្តម ណុះ ស្លេះ** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា អមដំណើរដោយ **ឯកឧត្តម សុះ ហ្វាសុី** និង**ឯកឧត្តម ពាស់ មូស្លីម** អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល ដឹកនាំគណៈប្រតិភូជាថ្នាក់ដឹកនាំពាក់ព័ន្ធ ចុះពង្រឹងយន្តការដឹកនាំ និងគ្រប់គ្រង វិស័យអប់រំឥស្លាមកម្ពុជា ដែលមានការចូលរួមពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំនៃរដ្ឋបាលក្រុង ស្រុក។











*Mondol Kiri Province: October 18, 2020, the Inspection and Teaching Inspection Ceremony was chaired by H.E Nos Sles, Secretary of State of the Ministry of Education, Youth and Sports, accompanied by H.E Sos Fasy, Undersecretary of State of the Ministry of Education Youth and Sport, Director of Khmer Islam Education and Khmer Islam Teachers at Department of Education youth and sport in Mondol Kiri Province.*

4. ខេត្តកំពត Kampot Province៖ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ **ឯកឧត្តម ណុះ ស្លេះ** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា អមដំណើរដោយ **ឯកឧត្តម សុះ ហ្វាស៊ី** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា **ឯកឧត្តម វេជ្ជ. ពាស់ មូស្លីម** អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល ដឹកនាំគណៈប្រតិភូជាថ្នាក់ដឹកនាំពាក់ព័ន្ធ ចុះពង្រឹងយន្តការដឹកនាំ និងគ្រប់គ្រង វិស័យអប់រំឥស្លាមកម្ពុជា ដែលមានការចូលរួមពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំនៃរដ្ឋបាលក្រុង ស្រុក។








*Kompot Province: January 16, 2021, the Inspection and Teaching Inspection Ceremony was chaired by H.E Nos Sles, Secretary of State of the Ministry of Education, Youth and Sports, accompanied by H.E Sos Fasy, Undersecretary of State of the Ministry of Education Youth and Sport, of Khmer Islam Education and Khmer Islam Teachers at Kompot Province.*

5. ខេត្តពោធិ៍សាត់ Pursat Province៖ ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២១ **ឯកឧត្តម ណុះ ស្លេះ** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា បានដឹកនាំអង្គប្រជុំស្តីពី "ពង្រឹងយន្តការដឹកនាំនិងគ្រប់គ្រងវិស័យអប់រំឥស្លាមកម្ពុជា តាមរយៈការអប់រំឥស្លាមនៅតាមមូលដ្ឋានខេត្តពោធិ៍សាត់" មានការចូលរួមពី **ឯកឧត្តម សុះ ហ្វាស៊ី** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា **ឯកឧត្តមវេជ្ជបណ្ឌិត ពាស់ មូស្លីម** អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល និង **លោក ស៊ឹម ម៉ាត់ទោត** តំណាងគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា ព្រមទាំងក្រុមការងារគណៈកម្មការសម្របសម្រួលការងារអប់រំឥស្លាម និងក្រុមការងារយុវជន CMYA ខេត្តពោធិ៍សាត់។






***Pursat Province: February 03, 2021, the Inspection and Teaching Inspection Ceremony was chaired by H.E Nos Sles, Secretary of State of the Ministry of Education, Youth and Sports, accompanied by H.E Sos Fasy, Undersecretary of State of the Ministry of Education Youth and Sport, H.E Dr. Pas Muslim, Undersecretary of State, Ministry of Health, Director of Khmer Islam Education and Khmer Islam Teachers at Pursat Province.***

6. ខេត្តកំពង់ធំ Kampong Thom Province៖ ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ កិច្ចប្រជុំពីការចុះពិនិត្យដំណើការបង្រៀន និងរៀន ក្រោមអធិបតីភាព **ឯកឧត្តម ណុះ ស្លេះ** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា អមដំណើរដោយ **ឯកឧត្តម សុះ ហ្វាស៊ី** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា និងមានការអញ្ជើញចូលរួមតំណាងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលស្រុក នាយកអប់រំខ្មែរឥស្លាម និងគ្រូបង្រៀនខ្មែរឥស្លាម។











*Kampong Thom Province: August 22, 2022, the Inspection and Teaching Inspection Ceremony was chaired by H.E Nos Sles, Secretary of State of the Ministry of Education, Youth and Sports, accompanied by H.E Sos Fasy, Undersecretary of State of the Ministry of EducationYouth and Sport, Director of Khmer Islam Education and Khmer Islam Teachers.*

7. ខេត្តកំពង់ឆ្នាំង Kampong Chhnang Province: ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២ កិច្ចប្រជុំពីការចុះពិនិត្យដំណើការបង្រៀន និងរៀនរបស់គ្រូបង្រៀនខ្មែរឥស្លាម ក្រោមអធិបតីភាព **ឯកឧត្តម ណុះ ស្លេះ** រដ្ឋលេខាធិការក្រសួងអប់រំយុវជននិងកីឡា ដែលអមដំណើរដោយ **ឯកឧត្តម សុះ ហ្វាស៊ី** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ប្រធានមន្ទីរអប់រំយុវជន និងកីឡាខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលស្រុក នាយកអប់រំខ្មែរឥស្លាម និងគ្រូបង្រៀនខ្មែរឥស្លាម។








*Kampong Chnang Province: August 25, 2022, the Inspection and Teaching Inspection Ceremony was chaired by H.E Nos Sles, Secretary of State of the Ministry of Education, Youth and Sports, accompanied by H.E Sos Fasy, Undersecretary of State of the Ministry of EducationYouth and Sport, Director of Khmer Islam Education and Khmer Islam Teachers.*

8. ខេត្តក្រចេះ Kratie Province៖ ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២២ កិច្ចប្រជុំពីការចុះពិនិត្យដំណើរការបង្រៀន និងរៀនរបស់គ្រូបងៀនខ្មែរឥស្លាម ក្រោមអធិបតីភាព **ឯកឧត្តម ណុះ ស្លេះ** រដ្ឋលេខាធិការក្រសួងអប់រំយុវជន និងកីឡា អមដំណើរដោយ **ឯកឧត្តមវេជ្ជ.ពាស់ មូស្លីម** អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលស្រុក និងនាយកគ្រប់គ្រងគ្រូបង្រៀនខ្មែរឥស្លាមខេត្ត នៅវិទ្យាល័យសិលាវេទី គាត ឈុន ខេត្តក្រចេះ។







*Kratie Province: August 28, 2022, the Inspection and Teaching Inspection Ceremony was chaired by H.E Nos Sles, Secretary of State of the Ministry of Education, Youth and Sports, accompanied by H.E Sos Fasy, Undersecretary of State of the Ministry of Education Youth and Sport, H.E Dr. Pas Muslim, Undersecretary of State, Ministry of Health, Director of Khmer Islam Education and Khmer Islam Teachers at Seila Veti Keat Chhun High School, Kratie Province.*

9. ខេត្តបាត់ដំបង Battambong Province៖ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២២ កិច្ចប្រជុំពីការចុះពិនិត្យដំណើការបង្រៀន និងរៀនរបស់គ្រូបង្រៀនខ្មែរឥស្លាម ក្រោមអធិបតីភាព **ឯកឧត្តម ណុះ ស្លេះ** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា អមដំណើរដោយ អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុក និងនាយកគ្រប់គ្រងគ្រូបង្រៀនខ្មែរឥស្លាមខេត្ត នៅមន្ទីរអប់រំយុវជននិងកីឡា ខេត្តបាត់ដំបង។







*Battambong Province: September 02, 2022, the Inspection and Teaching Inspection Ceremony was chaired by H.E Nos Sles, Secretary of State of the Ministry of Education, Youth and Sports, accompanied by, Director of Khmer Islam Education and Khmer Islam Teachers at Department of Education youth and Sport in Battambong Province*

## សកម្មភាព ឯកឧត្តម ណុះ ស្លេះ រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា ចុះត្រួតពិនិត្យ ដំណើរការរៀន និងបង្រៀន តាមសហគមន៍ឥស្លាម

Activities of H.E Nos Sles Secretary of State of Ministry of Education, Youth and Sports to Monitoring of Process of teaching in the Muslim community






















الله
محمد
الله
محمد













## ២. ៤ សកម្មភាពការចុះត្រួតពិនិត្យ និងវាយតម្លៃ ( Educational Monitoring and Evaluation process )

### ២.៤.១ ការចុះផ្ទៀងផ្ទាត់ប្រវត្តិរូបគ្រូបង្រៀនខ្មែរឥស្លាមមុនចូលក្របខណ្ឌឆ្នាំ២០១៥







*សកម្មភាពចុះផ្ទៀងផ្ទាត់ប្រវត្តិរូបគ្រូបង្រៀនខ្មែរឥស្លាមមុនចូលក្របខណ្ឌឆ្នាំ២០១៥*

***Activities of verifying the profile of Khmer Muslim teachers before entering the framework of 2015***

## ២.៤.២ សកម្មភាពការប្រឡងជ្រើសរើសគ្រូបង្រៀនខ្មែរឥស្លាមឆ្នាំ២០១៥



*សកម្មភាពការប្រឡងជ្រើសរើសគ្រូបង្រៀនខ្មែរឥស្លាមឆ្នាំ២០១៥*

***Activities of Khmer Islam Teacher Selection Exam 2015before entering the framework of 2015***

## ២.២.៣ ការបំពេញឯលសារសាលាកបត្រព័ត៌មានគ្រូបង្រៀន (២០១៦-២០១៧)










*Activities Completing the School Newsletter Teacher Information (2016-2017)*

## ២.២.៤.ការចុះពិនិត្យ និងផ្ទៀងផ្ទាត់គ្រូជាប់កិច្ចសន្យាខ្មែរឥស្លាម(២០១៦-២០១៧)













*Activities Completing the School Newsletter Teacher Information (2016-2017)*

## ២.២.៥ ការចុះអធិការកិច្ច Inspection process of the MoEYS and Ministry of Public Works








*សកម្មភាព 28៖ សកម្មភាពចុះត្រួតពិនិត្យ និងអធិការកិច្ចរបស់ក្រសួងអយក និងក្រសួងមុខងារសាធារណៈ*

***Activity 28: Inspection and inspection activities of the Ministry of Public Works and the Ministry of Public Function***

## ២.៥ ក្រុមការងារថ្នាក់កណ្ដាល Islamic Education central committee meeting











*សកម្មភាព 29៖ ក្រុមលេខាធិការដ្ឋាននៃគណៈកម្មការសម្របសម្រួលការងារអប់រំឥស្លាម គណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា និងមន្ត្រីជំនាញរបស់ក្រសួងអប់រំ យុវជន និងកីឡា ចូលរួមកិច្ចប្រជុំពិភាក្សាស្ដីពីការរៀបចំគោលនយោបាយ ស្ដីពីការអប់រំឥស្លាម និងផែនការសកម្មភាព*

***Activity 29: The Secretariat of the Islamic Education Coordinating Committee, the Senior Islamic Leadership Committee of Cambodia and professional officials of the Ministry of Education, Youth and Sports attended a meeting on the preparation of Islamic Education Master Plan and Policy Issues .***

## ២.៥.១ វគ្គបណ្តុះបណ្តាលគ្រូបង្គោលមកពីរាជធានី ខេត្ត Training activities: Capacity building for Islamic teachers ( ToT )

គណៈកម្មការសម្របសម្រួលការងារអប់រំឥស្លាមនៃគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា បានរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់ថ្នាក់ដឹកនាំឥស្លាមមកពីរាជធានី ខេត្ត ដែលធ្វើបទបង្ហាញដោយក្រុមការងារទាំង៧ ធ្វើបទបង្ហាញមានប្រធានបទដូចជា៖

១. បទបញ្ជាផ្ទៃក្នុងគ្រូ និងសិស្ស ២. ការងារត្រៀមបវេសនកាល ៣. ភារកិច្ចរបស់នាយកសាលា
៤. សាលារៀនស្អាត ៥. ភារកិច្ចគ្រូបន្ទុកថ្នាក់ ៦. ការដាក់វិន័យបែបវិជ្ជមាន
៧. អនុក្រិត្យលេខ៥៦ ៨. តួនាទីអ៊ីម៉ាំ និងការគ្រប់គ្រង ៩. ស្តង់ដាសាលារៀនគម្រូ
១០. នីតិវិធីដំណើរការរៀបអាពាហ៍ពិពាហ៍តាមធម៌វិន័យសាសនាឥស្លាម ១១. បទបង្ហាញស្តីពីគ្រូគម្រូ









***The Islamic Education Coordinating Committee of the Senior Islamic Leadership Committee of Cambodia organized a capacity building course for Islamic leaders from the provincial capitals, presented by the seven working groups, with the following topics: Internal regulations of teachers and students, Pre-school work 3.Duties of the principal, Clean school, Duties of the teacher in charge of the 6th grade, Positive Discipline, Sub-Decree No. 56, The Role of Imam and Management, Standard school standard, Procedures for marriage in accordance with Islamic dharma, and Presentation on model teachers.***

## ២.៥.២ សកម្មភាពនៃកិច្ចប្រជុំនានាត្រៀមរៀបចំមហាសន្និបាតអប់រំឥស្លាម Islamic Education Congress on meeting process











*សកម្មភាព 30៖ កិច្ចប្រជុំក្រុមការងារគណៈកម្មការសម្របសម្រួលការអប់រំឥស្លាមនៃគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា ដឹកនាំដោយ ឯកឧត្តម ណុះ ស្លេះ រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា*

***Activity 30: Meeting of the Working Group on Islamic Education Coordination of the Senior Islamic Leadership Committee of Cambodia, chaired by HE Nou Sles, Secretary of State, Ministry of Education, Youth and Sports.***






សកម្មភាព 31៖ កិច្ចប្រជុំក្រុមការងារគណៈកម្មការសម្របសម្រួលការអប់រំឥស្លាមនៃគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា ដឹកនាំដោយ លោក សឹម ម៉ាត់ទោត និងលោក សុះ ហ្វៅស៊ី សមាជិកគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា

***Activity 31: Meeting of the Islamic Education Coordinating Committee of the Cambodian Islamic Supreme Council, chaired by Mr. Sim Matthot and Mr. Sos Fosi, Member of the Supreme Islamic Council of Cambodia.***













សកម្មភាព 32៖ កិច្ចប្រជុំក្រុមការងារបច្ចេកទេសរៀបចំមហាសន្និបាតអប់រំឥស្លាម

*Activity 32: Meeting of the Technical Working Group for the Islamic Education Conference*










*សកម្មភាព 33៖ កិច្ចប្រជុំក្រុមការងារលេខាធិការដ្ឋាន រៀបចំមហាសន្និបាតអប់រំឥស្លាម*

***Activity 33: Meeting of the Secretariat of the General Assembly of Islamic Education***

កិច្ចប្រជុំអនុគណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ *Finance and Supply Sub-Committee Meeting*





កិច្ចប្រជុំអនុគណៈពិធីការតុបតែងនិងដឹកជញ្ជូន *Meeting on Decoration and Transport Protocol Subcommittee*





កិច្ចប្រជុំអនុគណៈសុខភាពនិងអនាម័យ *Health and Hygiene Sub-Committee Meeting*





កិច្ចប្រជុំអនុគណៈសន្តិសុខ និងសណ្តាប់ធ្នាប់ *Security and Order Subcommittee Meeting*





កិច្ចប្រជុំអនុគណៈកម្មការ ពត៌មាននិងផ្សព្វផ្សាយ *Information and broadcast  Subcommittee Meeting*





កិច្ចប្រជុំអនុគណៈកម្មការ អភិវឌ្ឍន៍កម្មវិធីសិក្សានិងបោះពុម្ព *Printing and Curriculum development  Subcommittee Meeting*







## ២.៦ សកម្មភាពនាយកអប់រំឥស្លាមរាជធានី ខេត្ត *Provincial Islamic Education Activities*

### ២.៦.១ ខេត្តកំពង់ឆ្នាំង *Kampong Chhnang province*









## ២.៦.២ សហគមន៍ក្រុមកនអ៊ីម៉ាំសាន់ (ឧកញ៉ាឃ្លួរ) *Imam Sann Community group activities*
























T.HIM
11

## ២.៦.៣ ខេត្តពោធិ៍សាត់ *Pursat province*












## ២.៦.៤ ខេត្តត្បូងឃ្មុំ *Tboung Khmum province*

ស្រុកតំបែរ ***Tambe District***











## ស្រុកត្បូងឃ្មុំ *Tboung Khmum District*










## ២.៦.៥ បាត់ដំបង *Battambong province*






## ២.៦.៦ បន្ទាយមានជ័យ *Bantaymenchey province*





## ២.៧ សកម្មភាពតាមសាលារៀន *School Based Activitites*

### ២.៧.១ សកម្មភាពគ្រូ និងសិស្ស *Teachers and Students activities*








*សកម្មភាព 34៖ មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ រៀបចំពីធីសំណេះសំណាលជាមួយគ្រូបង្រៀនទូទាំងរាជធានីភ្នំពេញ*

*Activitiy34:* ***Phnom Penh office of Education meeting***





























































إشراف: مؤسسة RELIFE4LIFE







ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស
លេខ: ០០៤/១៥

**សេចក្តីប្រកាសព័ត៌មាន**

**ស្តីពីលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី**

**ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៥**

ថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០១៥ វេលាម៉ោង៨ និង៣០នាទី នៅវិមានសន្តិភាព មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងអាណត្តិទី៥ ដើម្បីឆ្លង៖

**១- សេចក្តីព្រាងច្បាប់ ស្តីពីគណនេយ្យ និងសវនកម្ម។**

**២- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការគ្រប់គ្រងរទេះរន្ទេះ។**

**៣- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មលើវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ការថែទាំផ្លូវថ្នល់ និងការបើកមន្ទីរពិសោធន៍ វិស័យផ្លូវថ្នល់។**

**៤- បញ្ហាផ្សេងៗ៖** សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិបញ្ញត្តិលើ៖

៤.១-កិច្ចព្រមព្រៀង ស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ចរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបេឡារុស

៤.២-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសហព័ន្ធរុស្ស៊ី ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគទុន

ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ៤១ មហាវិថីសហព័ន្ធរុស្ស៊ី
ទូរសារលេខ: ០២៣ ២១២ ៩៤០, ទូរស័ព្ទ: ០១២ ៨៨៨ ៩៣៦, ០៩៧ ៧ ៩៧០ ៦០៨
អ៊ីមែល: pressocm@gmail.com

៤.៣-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបេឡារុស ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ

ក្រោយពីបានស្តាប់របាយការណ៍ និងមតិពិភាក្សាផ្លាស់ប្តូរយោបល់រួចមក កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានសម្រេចអនុម័ត៖

**១- សេចក្តីព្រាងច្បាប់ ស្តីពីគណនេយ្យ និងសវនកម្ម**

វិស័យគណនេយ្យ និងសវនកម្ម ជាផ្នែកមួយនៃវិស័យហិរញ្ញវត្ថុ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការថែរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងបានកំពុងរួមចំណែកយ៉ាងសកម្មនៅក្នុងការជំរុញកំណើនសេដ្ឋកិច្ចរយៈពេលវែងប្រកបដោយចីរភាព។ ផ្អែកលើទស្សនវិស័យនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ដែលបានគ្របដណ្តប់មួយផ្នែកលើវិស័យគណនេយ្យ និងសវនកម្ម ហៅថា "ចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ សម្រាប់ឆ្នាំ២០០១-២០១០" ដែលត្រូវបានធ្វើបច្ចុប្បន្នកម្មទៅជា "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥" ហើយបន្តមកទៀតជា "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០"។

ការរីកចម្រើននៃវិស័យធុរកិច្ច គឺជាកត្តាមោទនភាពដ៏ធំធេងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលសបញ្ជាក់ឲ្យឃើញនូវវឌ្ឍនភាពនៃសេដ្ឋកិច្ចកម្ពុជា នៅក្នុងបរិការណ៍នៃសុខសន្តិភាព, ស្ថេរភាពនយោបាយ និងកំណើននៃសមាហរណកម្មកម្ពុជាបច្ចុប្បន្ន។ ក៏ប៉ុន្តែកំណើននៃវិស័យធុរកិច្ចនេះ ក៏បានចោទជាបញ្ហាប្រឈមផងដែរ សម្រាប់ការរៀបចំគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុមួយឲ្យបានសមស្រប ទៅតាមការរីកលូតលាស់នៃវិស័យឯកជនដើម្បីទ្រទ្រង់សន្ទុះ និងជំរុញថាមពលនៃវិស័យនេះបន្ថែមទៀត។ ក្នុងស្មារតីនេះ នៅក្នុងគោលដៅជំរុញអភិបាលកិច្ចល្អ រាជរដ្ឋាភិបាលដែលមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាសេនាធិការ ចាំបាច់ត្រូវបន្តអភិវឌ្ឍក្របខ័ណ្ឌ និងលើកកំពស់គុណភាពគណនេយ្យ និងសវនកម្ម ឲ្យសមជាស្នូលនៃរចនាសម្ព័ន្ធទ្រទ្រង់សម្រាប់ប្រព័ន្ធសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាព និងភាពជឿទុកចិត្តបាន។

សេចក្តីព្រាងច្បាប់ស្តីពី "គណនេយ្យ និងសវនកម្ម" ត្រូវបានរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ដើម្បីជំនួសឲ្យច្បាប់ស្តីពី "គណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ" ដែលបានប្រកាសដាក់ឲ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/ រកម/ ០៧០២/ ០១១ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០២។

សេចក្តីព្រាងច្បាប់នេះ ចែកជា ១៣ជំពូក និង ៣៩មាត្រា ដែលបានកំណត់បន្ថែមនូវចំណុច និងខ្លឹមសារសំខាន់មួយចំនួន បន្ថែមលើច្បាប់បច្ចុប្បន្នដូចជា វិសាលភាពនៃច្បាប់, មុខងារភារកិច្ចរបស់ស្ថាប័នបញ្ញត្តិករ និងស្ថាប័នវិជ្ជាជីវៈ, យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តច្បាប់ និងស្តង់ដា, វិធានក្នុងការគ្រប់គ្រងវិស័យគណនេយ្យ និងសវនកម្ម និងក្រុមហ៊ុនសវនកម្ម ទណ្ឌកម្មចំពោះការបំពាននានា និងបទប្បញ្ញត្តិសំខាន់ៗមួយចំនួនទៀត។

សេចក្តីព្រាងច្បាប់ស្តីពី "គណនេយ្យ និងសវនកម្ម" ត្រូវបានរៀបចំឡើងដោយមន្ត្រីជំនាញរបស់កម្ពុជាសុទ្ធសាធដោយចំណាយពេលប្រមាណជិត៥ឆ្នាំ ដើម្បីឆ្លើយតបបានទាំងស្រុងទៅនឹងស្តង់ដាគណនេយ្យ និងសវនកម្មអន្តរជាតិ និងតំបន់ដែលមានសារៈសំខាន់ នៅក្នុងបរិការណ៍សមាហរណកម្មកម្ពុជា ទៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន។

សេចក្តីព្រាងច្បាប់នេះ នឹងមានវិសាលភាពអនុវត្តចំពោះស្ថាប័នសាធារណៈ សហគ្រាស អង្គភាពមិនស្វែងរកប្រាក់ចំណេញ គណនេយ្យករនិងសវនករ។ ច្បាប់នេះមិនអនុវត្តចំពោះធនាគារកណ្តាល និងតួនាទីភារកិច្ចដែលជាសមត្ថកិច្ចរបស់អាជ្ញាធរសវនកម្មជាតិទេ។

## ២- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការគ្រប់គ្រងអាងទន្លេ

ជោគជ័យនៃការរីកចំរើនសេដ្ឋកិច្ចដ៏ល្អប្រសើរ របស់រាជរដ្ឋាភិបាល និងគោលនយោបាយដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើឲ្យកម្ពុជាក្លាយទៅជាប្រទេសមានចំណូលមធ្យមក្នុងកម្រិតទាប ជាមួយគ្នានេះ វិស័យធនធានទឹកក៏មានការរីកចម្រើនឡើងគួរឲ្យកត់សំគាល់ផងដែរ។ ទន្ទឹមនឹងការរីកចម្រើននេះ យើងបានសង្កេតឃើញថាមានការកើតមានឡើងភាពអនាធិបតេយ្យនៃការប្រើប្រាស់ទឹក និងសកម្មភាពរបស់មនុស្សដទៃទៀតនៅតំបន់ទីជម្រាលមាត់សមុទ្រ និងតាមបណ្តាស្ទឹងនីមួយៗនៃព្រះរាជាណាចក្រកម្ពុជា ដែលជាការបង្កើតសម្ពាធមកលើធនធានទឹក និងឈានដល់ការប្រឈមមុខទៅនឹងកង្វះទឹកប្រើប្រាស់ និងសុខមាលភាពរបស់ប្រជាពលរដ្ឋទាក់ទងទៅនឹងទឹកដែលមានជាតិពុល ភាពកង្វក់មិនអាចគ្រប់គ្រងបាន។

ក្នុងគោលបំណងធានាបាននូវនិរន្តរភាពនៃបរិស្ថានទឹក និងការប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាព និងសុខមាលភាពរបស់ប្រជាជន ស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចកម្ពុជា និងការធ្វើកំណែទម្រង់គោលនយោបាយ របស់រាជរដ្ឋាភិបាលស្របទៅតាមច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានប្រកាសដាក់ឲ្យប្រើជាផ្លូវការនៅឆ្នាំ២០០៧ ក្រសួងធនធានទឹក និងឧតុនិយមបានរៀបចំសេចក្តីព្រាងអ

អនុក្រឹត្យស្តីពី ការគ្រប់គ្រងអាងទន្លេ ដែលមាន៧ជំពូក ចែកចេញជា២៧មាត្រា។ តាមរយៈនៃអនុក្រឹត្យនេះ គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ និងគណៈកម្មាធិការរាជធានីខេត្តគ្រប់គ្រងអាងទន្លេត្រូវបានបង្កើតឡើង។

**៣- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មលើវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ការថែទាំផ្លូវថ្នល់ និងការបើកមន្ទីរពិសោធន៍ វិស័យផ្លូវថ្នល់។**

សេចក្តីព្រាងអនុក្រឹត្យ ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មលើវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ការថែទាំផ្លូវថ្នល់ និងការបើកមន្ទីរពិសោធន៍វិស័យផ្លូវថ្នល់នេះមាន ៩ជំពូក និង២៣មាត្រា។

អនុក្រឹត្យនេះរៀបចំដោយក្រសួងសាធារណៈការ និងដឹកជញ្ជូន មានវិសាលភាពអនុវត្តចំពោះអង្គភាពដែលអនុវត្តការងារពាក់ព័ន្ធនឹងវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងបុគ្គលដែលប្រកបអាជីវកម្មពាក់ព័ន្ធនឹងវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ការថែទាំផ្លូវថ្នល់ ការផ្តល់សេវាទីប្រឹក្សាបច្ចេកទេសសំណង់ផ្លូវថ្នល់ ការសិក្សាគម្រោងប្លង់ ការត្រួតពិនិត្យសំណង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងការបើកមន្ទីរពិសោធន៍វិស័យផ្លូវថ្នល់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**៤- បញ្ហាផ្សេងៗ៖**

អង្គប្រជុំគណៈរដ្ឋមន្ត្រីបានសម្រេចបញ្ជូន៖

១-កិច្ចព្រមព្រៀង ស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ចរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបេឡារុស

២-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសហព័ន្ធរុស្ស៊ី ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ

៣-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបេឡារុស ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិ។

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានក្រើនរំលឹកដល់ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ សហការជាមួយ[illegible]

គណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា អនុវត្តឲ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាពចំពោះសេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ៧០៣ ស.ជ.ណ.អរ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០១៥ ស្តីពីការសម្រេចរបស់សម្តេចក្នុងការយល់ព្រមបញ្ចូលគ្រូបង្រៀនខ្មែរឥស្លាមចំនួន ១៥០០ នាក់ ទៅក្នុងក្របខ័ណ្ឌគ្រូបង្រៀននៃក្រសួងអប់រំយុវជន និងកីឡា ដោយទទួលបានប្រាក់បៀវត្សរ៍ចាប់ពីខែសីហា ឆ្នាំ២០១៥ តទៅ។ ដោយឡែកក្រសួងមហាផ្ទៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវសហការអនុវត្តឲ្យមានប្រសិទ្ធភាពនូវសេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ៧០៤ ស.ជ.ណ ផក ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០១៥ ស្តីពីការយល់ព្រមរបស់សម្តេចអនុញ្ញាតឲ្យបុរសពាក់កន្តិប និងស្ត្រីឥស្លាមទទ្រក្បាលធ្វើលិខិតឆ្លងដែន អត្តសញ្ញាណប័ណ្ណ ឬថតរូបសម្រាប់ឯកសាររដ្ឋបាលផ្សេងៗប្រសិនបើបងប្អូនចង់គ្របក្បាល។ ចាងហ្វាងគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា ប្រធានអង្គការមូលនិធិអភិវឌ្ឍន៍មូស្លីមកម្ពុជា ត្រូវសហការផ្សព្វផ្សាយសេចក្តីជូនដំណឹងនេះឲ្យបានទូលំទូលាយជូនដល់ប្រជាពលរដ្ឋខ្មែរឥស្លាម។

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានណែនាំឲ្យធ្វើការសិក្សាឡើងវិញនូវផលប្រយោជន៍ និងផលប៉ះពាល់ពីការអនុញ្ញាតឲ្យនាវាបរទេសប្រើប្រាស់ទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជានាពេលកន្លងមក។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង១២ និង១៥នាទី។

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៥

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**
**លេខ:** ៥៧០៣ សជណ.សរ

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥

**គោរពជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**កម្មវត្ថុ៖** ករណីសំណើសុំគោលការណ៍ដើម្បីបញ្ចូលគ្រូបង្រៀនខ្មែរឥស្លាមចំនួនប្រមាណ ១៥០០ នាក់ ទៅក្នុងក្របខណ្ឌគ្រូបង្រៀន នៃក្រសួងអប់រំ យុវជន និងកីឡា។

**យោង ៖** - លិខិតលេខ២៦២៦ អយក.បល ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៥ របស់ក្រសួងអប់រំ យុវជន និងកីឡា
- ចំណាររបស់សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៥

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្ដីការគណៈរដ្ឋមន្ត្រីមានកិត្តិយសសូមជម្រាបជូន ឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ករណីសំណើសុំគោលការណ៍ដើម្បីបញ្ចូលគ្រូបង្រៀនខ្មែរឥស្លាមចំនួនប្រមាណ ១៥០០ នាក់ ទៅក្នុងក្របខណ្ឌគ្រូបង្រៀន នៃក្រសួងអប់រំ យុវជន និងកីឡា រាជរដ្ឋាភិបាលបានឯកភាពដូចខាងក្រោម៖

- យល់ព្រមតាមសំណើ
- ចាប់អនុវត្តពីខែសីហា ឆ្នាំ២០១៥ តទៅ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ សហការអនុវត្តឱ្យបានល្អ។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។

សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**
Thorak
បណ្ឌិត **ហ៊ីង ថូរ៉ាក់ស៊ី**

***ចម្លងជូន៖***
- *ក្រសួងធម្មការ និងសាសនា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *គណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា*
- *ប្រធានសមាគមការអភិវឌ្ឍន៍សហគមន៍មូស្លីមកម្ពុជា*
- *ឯកសារ កាលប្បវត្តិ*